# ខ និងលក្ខខណ្ឌនៃប័ណ្ណឥណទានរបស់ធនាគារ មេយប៊ែង

ការចេញប័ណ្ណវីសា (VISA) ឬ ប័ណ្ណអាមេរិកខេនអ៊ិចប្រេស្ស (AMEX) (មិនថាជាប័ណ្ណមេ ឬ ប័ណ្ណរង) ("ប័ណ្ណឥណទាន") ដោយធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី (“ធនាគារ” ឬ “ពួកយើង” ឬ “យើងខ្ញុំ”) ជូនលោកអ្នក ឬនៅក្នុងករណីប័ណ្ណឥណទានរងផ្តល់ជូនទៅសមាជិកប័ណ្ណឥណទានរង និងការប្រើប្រាស់ប័ណ្ណឥណទានដោយលោកអ្នកផ្ទាល់ ឬ សមាជិកប័ណ្ណឥណទានរងនឹងត្រូវគោរពតាម ខ និងលក្ខខណ្ឌ ដូចខាងក្រោម។ ខ និងលក្ខខណ្ឌទាំងនេះនឹងត្រូវអនុវត្តភ្លាមៗចំពោះលោកអ្នក នៅពេលដែលលោកអ្នក ឬ (សមាជិកប័ណ្ណឥណទានរង ប្រសិនបើមាន) ទទួលបានប័ណ្ណឥណទាន ឬ នៅពេលដែលលោកអ្នក ឬ(សមាជិកប័ណ្ណឥណទានរង ប្រសិនបើមាន) បើកដំណើរការ ឬប្រើប្រាស់ប័ណ្ណឥណទាន ឬ សកម្មភាពណាមួយដែលបានធ្វើមុន។

## ១. ការទទួលយកប័ណ្ណឥណទាន

១.១ លោកអ្នកត្រូវតែចុះហត្ថលេខាលើប័ណ្ណឥណទានភ្លាមៗនៅពេលដែលទទួលយកប័ណ្ណ។ ប្រសិនបើលោកអ្នកមិនយល់ព្រមជាមួយនឹង ខ និងលក្ខខណ្ឌទាំងនេះទេ លោកអ្នកត្រូវតែកាត់ប័ណ្ណឥណទាននោះជាពីរ ឬបំផ្លាញចោល។ ប្រសិនបើលោកអ្នកមិនអនុវត្តដូច្នេះទេ លោកអ្នកនឹងត្រូវចាត់ទុកថាបានយល់ព្រមចំពោះ ខ និងលក្ខខណ្ឌទាំងនេះដោយគ្មានខរក្សាទុក។

១.២ លោកអ្នកមិនត្រូវអនុញ្ញាត ឲ្យបុគ្គលផ្សេងទៀតប្រើប្រាស់ប័ណ្ណឥណទានរបស់លោកអ្នក ឬបង្ហាញលេខសម្ងាត់របស់លោកអ្នកទៅកាន់បុគ្គលណាម្នាក់ឡើយ។

## ២. មុខងារនៃប័ណ្ណឥណទាន

២.១ លោកអ្នកអាចប្រើប្រាស់ប័ណ្ណឥណទាន នៅក្នុងទំហំកម្រិតឥណទានណាមួយដូចដែលបានចែងនៅក្នុង ខ និងលក្ខខណ្ឌនេះ។

២.២ មុខងារសម្រាប់ការប្រើប្រាស់ជាមួយម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM/SRM) ត្រូវបានដាក់បញ្ចូលនៅក្នុងប័ណ្ណឥណទានរបស់លោកអ្នក ដែលអនុញ្ញាតឲ្យលោកអ្នកធ្វើប្រតិបត្តិការជាមួយធនាគារតាមរយៈប្រព័ន្ធអេឡិចត្រូនិច មិនថាតាមម៉ាស៊ីនស្វ័យប្រវត្តិ ម៉ាស៊ីនដែលអាចដំណើរការតាមបន្ទះឈីប ឬប្រតិបត្តិការផ្សេងៗទៀត។

មុខងារសម្រាប់ការប្រើប្រាស់ប័ណ្ណឥណទានរួមមាន៖

ក) ការទិញទំនិញ និង/ឬ សេវាកម្មពីបណ្តាអាជីវករ ដែលមានការអនុញ្ញាតត្រឹមត្រូវ ("អាជីវករ") និង

ខ) ការដកសាច់ប្រាក់ពីម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិណាមួយ។ ធនាគារមានសិទ្ធិក្នុងការបន្ថែមមុខងារមួយ ឬច្រើនសម្រាប់ការប្រើប្រាស់ប័ណ្ណឥណទានគ្រប់ពេលវេលា។ ប្រសិនបើមានការបន្ថែម ខ និងលក្ខខណ្ឌសម្រាប់គ្រប់គ្រងការប្រើប្រាស់ សេវាកម្មនោះនឹងត្រូវបានកំណត់នៅក្នុង ខ និងលក្ខខណ្ឌបន្ថែម។

## ៣. ការប្រើប្រាស់ប័ណ្ណឥណទាន

៣.១ លោកអ្នកត្រូវប្រើប្រាស់ប័ណ្ណឥណទានតាមរបៀបដូចខាងក្រោម៖

ក) ការទិញទំនិញពីបណ្តាអាជីវករ៖

(i) លោកអ្នកត្រូវបញ្ចូលលេខសម្ងាត់របស់លោកអ្នកនៅពេលធ្វើប្រតិបត្តិការ ឬ

(ii) លោកអ្នកត្រូវចុះហត្ថលេខានៅលើវិក្កយបត្រដែលចេញដោយអាជីវករ ឬ

(iii) ក្នុងករណីទិញទំនិញដោយប្រយោល (ដូចជាការទិញដែលធ្វើឡើងតាមរយៈប្រព័ន្ធអ៊ីនធឺណែត ឬតាមរយៈអ៊ីម៉ែល ឬតាមរយៈទូរស័ព្ទ) លោកអ្នកអាចមានសិទ្ធិលើការបញ្ជាទិញដោយមិនចាំបាច់ចុះហត្ថលេខាលើវិក្កយបត្រលក់ ឬវាយបញ្ចូលលេខសម្ងាត់របស់លោកអ្នកនោះទេដោយគ្រាន់តែផ្តល់នូវលេខប័ណ្ណឥណទានរបស់លោកអ្នករួមនឹងព័ត៌មានលម្អិតផ្សេងៗ ដែលមានបញ្ជាក់នៅលើប័ណ្ណឥណទានទៅឲ្យអាជីវករ។

ខ) ការដកសាច់ប្រាក់នៅតាមបញ្ជរដកប្រាក់ដែលមានការអនុញ្ញាត៖

(i) លោកអ្នកត្រូវចុះហត្ថលេខានៅលើវិក្កយបត្រដកសាច់ប្រាក់ ដែលបានរៀបចំដោយបញ្ជរដកប្រាក់។

គ) ការដកសាច់ប្រាក់តាមរយៈម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM/SRM)៖

(i) លោកអ្នកត្រូវប្រើប្រាស់លេខសម្ងាត់របស់លោកអ្នក ដើម្បីធ្វើប្រតិបត្តិការ នៅលើគណនីនៃប័ណ្ណឥណទាន។

៣.២ ការកាត់ទឹកប្រាក់ពីគណនីប័ណ្ណឥណទាន

ក) ធនាគារនឹងធ្វើការកាត់ទឹកប្រាក់ចេញពីគណនីប័ណ្ណឥណទានរបស់លោកអ្នកនូវចំនួនទឹកប្រាក់ដែលបានទិញ និងចំនួនទឹកប្រាក់ដែលបានដកជាសាច់ប្រាក់សរុបទាំងអស់ ដែលធ្វើឡើងតាមរយៈការប្រើប្រាស់ប័ណ្ណឥណទានរបស់លោកអ្នក។

ខ) លោកអ្នក ត្រូវអនុញ្ញាតឲ្យធនាគារកាត់ទឹកប្រាក់ចេញពី គណនីប័ណ្ណឥណទានរបស់លោកអ្នក សម្រាប់ការទិញ ឬការដកសាច់ប្រាក់នីមួយៗ ដែលបង្ហាញនៅក្នុងវិក្កយបត្រទំនិញ ឬវិក្កយបត្រដកសាច់ប្រាក់។ ចំនុចនេះនឹងត្រូវអនុវត្តទោះបីជាអាជីវករបានកាត់ប្រាក់លើស ឬខ្វះក៏ដោយ។

៣.៣ លោកអ្នក ត្រូវអនុលោមតាមលក្ខខណ្ឌ សេចក្តីណែនាំ និងគោលការណ៍ទាំងអស់ ដែលចេញដោយធនាគារ ដែលទាក់ទងនឹងការប្រើប្រាស់ប័ណ្ណឥណទាន និងសេវាពាក់ព័ន្ធដែលបានផ្តល់ជូនលោកអ្នក។

៣.៤ លោកអ្នកយល់ព្រមចំពោះការកត់ត្រានៃប្រតិបត្តិការរបស់ធនាគារពីប័ណ្ណឥណទានរបស់ លោកអ្នកដោយរួមបញ្ចូលនូវកាតព្វកិច្ចលោកអ្នក ហើយជាភស្តុតាងនៃបំណុលរបស់លោកអ្នកនឹងត្រូវបានកត់ត្រាទៅក្នុងគណនីប័ណ្ណឥណទានរបស់លោកអ្នក។

៣.៥ លោកអ្នក មិនគួរប្រើប័ណ្ណឥណទានរបស់លោកអ្នក នៅក្នុងគោលបំណងនៃការភ្នាល់ រួមទាំងការទិញសន្លឹកឆ្នោត ការទិញកាក់លេងល្បែងនៅកាស៊ីណូ ការភ្នាល់ក្រៅផ្លូវការ និងការភ្នាល់លើការប្រណាំងនោះទេ។ ប្រសិនបើលោកអ្នកធ្វើដូច្នេះ ប្រតិបត្តិការទាំងនេះនឹងត្រូវបានចាត់ទុកថាជាការដកសាច់ប្រាក់ហើយធនាគារនឹងគិតថ្លៃសេវាដកសាច់ប្រាក់ដែលពាក់ព័ន្ធទៅតាមប្រតិបត្តិការនីមួយៗ។

## ៤. គណនីប័ណ្ណឥណទាន

៤.១ លោកអ្នកអាចដាក់ពាក្យស្នើសុំរបាយការណ៍អេឡិចត្រូនិចប្រចាំខែរបស់គណនី ឬស្នើសុំរបាយការណ៍ប្រចាំខែជាច្បាប់បោះពុម្ពលើក្រដាស ដែលបង្ហាញពីទឹកប្រាក់នៃការចំណាយលើប័ណ្ណឥណទានដែលលោកអ្នកបានប្រើប្រាស់ និងសមតុល្យសាច់ប្រាក់ក្នុងគណនីប័ណ្ណឥណទានរបស់លោកអ្នក។

៤.២ កំណត់ត្រានិងការចុះក្នុងរបាយការណ៍គណនីប្រចាំខែរបស់លោកអ្នកត្រូវចាត់ទុកថាត្រឹមត្រូវ និងភ្ជាប់កាតព្វកិច្ចរបស់លោកអ្នក ប្រសិនបើធនាគារមិនទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដើម្បីជំទាស់ក្នុងរយៈពេល ២០ថ្ងៃ បន្ទាប់ពីថ្ងៃបិទបញ្ជីនៃរយៈពេលចេញវិក្កយបត្រ ដែលពាក់ព័ន្ធដូចដែលបានបង្ហាញនៅលើរបាយការណ៍គណនីនោះ។

៤.៣ ប្រសិនបើធនាគារទទួលបានការជូនដំណឹងនៅក្នុងរយៈពេលដែលបានកំណត់នោះធនាគារនឹងពិនិត្យមើលគណនីប័ណ្ណឥណទានរបស់លោកអ្នកហើយនឹងធ្វើការកែសម្រួលនិងកែតម្រូវឡើងវិញទៅតាមអ្វីដែលធនាគារគិតថាសមស្រប។ ប្រការនេះនឹងមិនប៉ះពាល់ដល់កាតព្វកិច្ចរបស់លោកអ្នកដែលមានចែងក្នុងប្រការ ៧ នោះទេ។

## ៥. កម្រិតឥណទាន

៥.១ តាមឆន្ទានុសិទ្ធិរបស់ធនាគារក្នុងការកែសម្រួលកម្រិតឥណទានរបស់លោកអ្នកនៅពេលណាមួយ (រួមបញ្ចូលទាំងការកាត់បន្ថយកម្រិតឥណទានផងដែរ) ដោយមិនចាំបាច់ធ្វើការជូនដំណឹង ឬផ្តល់ហេតុផលណាមួយជូនលោកអ្នក។ កម្រិតឥណទានថ្មីនឹងត្រូវអនុវត្តចាប់ពីថ្ងៃធ្វើការកែសម្រួលកម្រិតឥណទាន។ លោកអ្នកនឹង ត្រូវបានចាត់ទុកថាទទួលបានការជូនដំណឹង អំពីការកំណត់កម្រិតឥណទានថ្មី នៅពេលចេញរបាយការណ៍គណនីប្រចាំខែរបស់លោកអ្នកដែលបានបង្ហាញនូវកម្រិតឥណទានថ្មី។

៥.២ ប្រសិនបើលោកអ្នកមានគណនីប័ណ្ណឥណទានពីរ ឬច្រើនជាមួយធនាគារ ការកំណត់កម្រិតឥណទានរួមគ្នាដែលតំណាងឲ្យកម្រិតឥណទានសរុប ដោយបានបែងចែកទៅកាន់គណនីទាំងអស់ ត្រូវបានកំណត់ជូនលោកអ្នក។

៥.៣ លោកអ្នកមិនត្រូវប្រើប្រាស់លើសកម្រិតឥណទានរបស់លោកអ្នកនោះទេ ទោះបីក្នុងពេលណាមួយក៏ដោយ។ ប្រសិនបើមិនដូច្នេះទេ លោកអ្នកនឹងត្រូវបង់ចំនួនដែលលើសនេះភ្លាមៗនៅពេលទទួលបានរបាយការណ៍គណនីប្រចាំខែរបស់លោកអ្នក ។

៥.៤ ស្របតាមការត្រួតពិនិត្យរបស់ធនាគារ លោកអ្នកអាចធ្វើប្រតិបត្តិការដកប្រាក់ ដែលចំនួនទឹកប្រាក់នោះមិនត្រូវលើសពីកម្រិតឥណទានរបស់លោកអ្នកឡើយដោយ៖

ក) ធ្វើការបង្ហាញប័ណ្ណឥណទាននៅតាមបញ្ជរដកប្រាក់ ដោយភ្ជាប់មកជាមួយ អត្តសញ្ញាណប័ណ្ណរបស់លោកអ្នក និងចុះហត្ថលេខានៅលើវិក្កយបត្រដកប្រាក់ ឬ

ខ) ប្រើប្រាស់ប័ណ្ណឥណទានរបស់លោកអ្នកនៅលើម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM/SRM) ណាមួយ ដោយការដកប្រាក់នឹងត្រូវកំណត់តាមចំនួនកំណត់នៃការដកប្រាក់ប្រចាំថ្ងៃ ឬតាមចំនួនកំណត់នៃការដកប្រាក់សម្រាប់ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM/SRM)។

៥.៥ តាមឆន្ទានុសិទ្ធិរបស់ធនាគារនឹងមិនចាំបាច់ផ្តល់នូវហេតុផលណាមួយឡើយ។ ធនាគារអាចកម្រិត (ដែលគិតតាមភាគរយនៃការកំណត់ឥណទានរបស់លោកអ្នក និង/ឬ សមតុល្យសាច់ប្រាក់របស់លោកអ្នកដែលអាចប្រើប្រាស់បាន) ចំនួនទឹកប្រាក់ដែលអាចដកបាន ហើយនឹងអាចកែប្រែក្នុងពេលណាមួយ (រួមទាំងការបន្ថយ)។

## ៦. វិវាទ

៦.១ រាល់វិវាទដែលបានកើតឡើងពីភាពខុសគ្នា ឬមិនដូចគ្នាដែលបានកើតឡើងលើរបាយកាណ៌គណនីរបស់ម្ចាស់ប័ណ្ណ ត្រូវដាក់បណ្តឹង ឬ រាយការណ៍មកធនាគារក្នុងរយៈពេល២០ថ្ងៃ ចាប់ពីថ្ងៃចេញរបាយការណ៍។ ប្រសិនបើមិនដូច្នេះទេ ត្រូវសន្មតជារួមថាម្ចាស់ប័ណ្ណ បានទទួលយកនូវរាល់ការចំណាយទាំងអស់ ដែលមាននៅក្នុងរបាយការណ៍។ បន្ថែមលើនេះទៀតម្ចាស់ប័ណ្ណត្រូវផ្តល់ព័ត៌មាន ដែលតម្រូវដោយធនាគារ ដើម្បីគាំទ្រដល់ការទាមទារឲ្យទូទាត់ មកវិញទៅតាមពេលវេលាដែលបានកំណត់។

៦.២ ក្នុងករណីម្ចាស់ប័ណ្ណមានវិវាទចំពោះប្រតិបត្តិការណាមួយ ធនាគារត្រូវធ្វើការស៊ើបអង្កេតលើប្រតិបត្តិការដែលមានវិវាទទៅតាមឆន្ទានុសិទ្ធិ របស់ខ្លួនដោយលក្ខខណ្ឌដូចខាងក្រោមនឹងត្រូវយកមកអនុវត្តៈ

ក) ប្រសិនបើការស៊ើបអង្កេតរបស់ធនាគាររកឃើញ ឬបញ្ជាក់ថាម្ចាស់ប័ណ្ណត្រូវទទួលខុសត្រូវ នូវប្រតិបត្តិការដែលមានវិវាទធនាគារមានសិទ្ធិបន្ថែមការចំណាយដូចខាងក្រោមនេះ៖

(i) យកថ្លៃសេវានៃការស៊ើបអង្កេតដប់ (១០)ដុល្លារអាមេរិក សម្រាប់មួយប្រតិបត្តិការ

(ii) ការប្រាក់នឹងត្រូវគិតរហូតដល់ការស៊ើបអង្កេតបានបញ្ចប់ដោយធនាគារ

(iii) មិនយកការប្រាក់ និង/ឬ ថ្លៃសេវាសម្រាប់ការស៊ើបអង្កេតក្នុងករណីរកឃើញថាម្ចាស់ប័ណ្ណមិនមានកំហុសចំពោះប្រតិបត្តិការដែលមានវិវាទ។

ខ) ការរកឃើញរបស់ធនាគារ មេឃប៉ែង ដែលបានធ្វើឡើងទៅលើគណនីប័ណ្ណឥណទាននឹងត្រូវបានដាក់ចូលជាកាតព្វកិច្ចរបស់ម្ចាស់ប័ណ្ណលុះត្រាតែមានភស្តុតាងផ្សេងទៀតមកបញ្ជាក់។

៦.៣ រាល់វិវាទដែលមានចំនួនទឹកប្រាក់តិចជាង២៥ដុល្លារ ក្នុងមួយប្រតិបត្តិការ នឹងមិនអាចទាមទារឲ្យទូទាត់មកវិញនោះទេ សម្រាប់ប័ណ្ណឥណទានអាមេរិកខេនអិចប្រេស្ស។

## ៧. ការទូទាត់

៧.១ នៅពេលលោកអ្នកទទួល (ឬចាត់ទុកថាបានទទួល) របាយការណ៍គណនីប្រចាំខែនៃប័ណ្ណឥណទានរបស់លោកអ្នកនោះ លោកអ្នកត្រូវធ្វើការទូទាត់ដូចខាងក្រោមៈ

ក) បង់ចំនួនសរុបនៃសមតុល្យសរុបចុងគ្រា នៅ/ឬ មុនថ្ងៃផុតកំណត់

ខ) ធ្វើការទូទាត់អប្បបរមាដូចខាងក្រោម៖

(i) នៅពេលដែលចំនួនសមតុល្យសាច់ប្រាក់សរុបចុងគ្រា ស្ថិតក្នុងកម្រិតនៃឥណទានរបស់លោកអ្នកចំនួនឥណទានដែលត្រូវទូទាត់សរុបមិនត្រូវតិចជាងដប់ភាគរយ (១០%) នៃចំនួនសមតុល្យសាច់ប្រាក់ចុងគ្រា ឬស្ថិតនៅក្រោមអប្បបរមានៃចំនួន ដប់ (១០) ដុល្លារអាមេរិកប៉ុណ្ណោះ ឬ

(ii) នៅពេលដែលចំនួនសមតុល្យសាច់ប្រាក់សរុបចុងគ្រា លើសពីកម្រិតនៃឥណទានរបស់លោកអ្នកចំនួនឥណទានដែលត្រូវទូទាត់សរុបមិនត្រូវតិចជាងដប់ភាគរយ (១០%) នៃចំនួនសមតុល្យសាច់សរុបចុងគ្រា (ប៉ុន្តែរួមបញ្ចូលទាំងចំនួនដែលមិនបានបង់កាលពីមុនដូចដែលមាននៅលើរបាយការណ៍

គណនីប្រចាំខែ)។

៧.២ ការប្រាក់នឹងត្រូវបូកបន្ថែមទៅលើបំណុល ដែលកើតចេញពីការធ្វើប្រតិបត្តិការទិញ និង/ឬ ការធ្វើប្រតិបត្តិការដកប្រាក់ ។

សម្រាប់ប្រតិបត្តិការទិញ ការប្រាក់នឹងត្រូវគណនា ដូចខាងក្រោម៖

- សម្រាប់ប្រតិបត្តិការនៅក្នុងរបាយការណ៍ទីមួយ៖ ប្រសិនបើទឹកប្រាក់សរុបនៅក្នុងរបាយការណ៍ មិនត្រូវបានបង់ពេញលេញ នោះទឹកប្រាក់ដែលនៅសល់នឹងត្រូវបានគណនាការប្រាក់ ចាប់ពីថ្ងៃផុតកំណត់រហូតដល់ថ្ងៃបានបង់ប្រាក់ពេញលេញ។
- សម្រាប់ប្រតិបត្តិការនៅក្នុងរបាយការណ៍ទី២ និងរបាយការណ៍បន្តបន្ទាប់ទៀត៖ ប្រសិនបើទឹកប្រាក់សរុបនៅក្នុងរបាយការណ៍ មិនត្រូវបានបង់ពេញលេញ នោះទឹកប្រាក់ដែលនៅសល់ពីប្រតិបត្តិការថ្មីៗនឹងត្រូវបានគណនាការប្រាក់ ចាប់ពីថ្ងៃធ្វើប្រតិបត្តិការរហូតដល់ថ្ងៃបានបង់ប្រាក់ពេញលេញ។

សម្រាប់ការដកប្រាក់ ការប្រាក់នឹងត្រូវគណនា ចាប់ពីថ្ងៃធ្វើប្រតិបត្តិការ រហូតដល់ថ្ងៃបានបង់ប្រាក់ពេញលេញ។

អត្រាការប្រាក់ នឹងត្រូវបានកំណត់ដោយធនាគារ។ ការគណនាការប្រាក់នឹងអនុវត្តតាមការកំណត់ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ១។

៧.៣ ប្រសិនបើការទូទាត់អប្បបរមាមិនត្រូវបានបង់មកធនាគារតាមកាលបរិច្ឆេទដែលបានកំណត់ ប្រាក់ពិន័យលើការបង់យឺតនឹងត្រូវគិត ១% នៃចំនួនសមតុល្យសាច់ប្រាក់ដែលមិនទាន់បង់ ឬ ដប់ (១០) ដុល្លារអាមេរិកដោយយកអត្រាណាខ្ពស់ជាង។

៧.៤ ធនាគារនឹងអនុវត្តការទូទាត់ណាមួយដែលផ្តល់ជូនលោកអ្នកតាមចំនួននៃសមតុល្យសាច់ប្រាក់ដែលមានអត្រាការប្រាក់ខ្ពស់ដល់អត្រាការប្រាក់ទាបបំផុត។

៧.៥ ការទូទាត់ទាំងអស់របស់លោកអ្នកមកកាន់ធនាគារនឹងមិនត្រូវបានធ្វើឡើង ដោយមានការកាត់បន្ថយណាមួយឡើយ (មិនថាផ្អែកលើការទាមទារ ឬការតវ៉ា ឬសិទ្ធិនៃការកំណត់ដែលលោកអ្នកគិតថាលោកអ្នកអាចមានសិទ្ធិតវ៉ាទៅនឹងអាជីវករ ឬ បញ្ជរដកប្រាក់ ឬក្រៅពីនេះ)។

## ៨. ថ្លៃសេវា និងកម្រៃផ្សេងៗ

៨.១ លោកអ្នកនឹងធ្វើការទូទាត់ និងអនុញ្ញាតឲ្យធនាគារកាត់ថ្លៃសេវាចេញពីគណនីប័ណ្ណឥណទានរបស់លោកអ្នកតាមចំនួនថ្លៃសេវា និងកម្រៃផ្សេងៗដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ២ នៃ ខ និងលក្ខខណ្ឌនេះ។

ធនាគារអាចនឹងកែប្រែឡើងវិញចំពោះថ្លៃសេវា និងកម្រៃផ្សេងៗ នៅពេលណាមួយ (រួមទាំងការផ្លាស់ប្តូរប្រភេទ ឬចំនួនទឹកប្រាក់ នៃថ្លៃសេវា និងកម្រៃផ្សេងៗ) ដោយធ្វើវិសោធនកម្មក្នុងឧបសម្ព័ន្ធ ២ ឬ ចេញសេចក្តីជូនដំណឹងពីការកែប្រែ ឬ ធ្វើការផ្សព្វផ្សាយពីការកែប្រែនោះ តាមរយៈបណ្តាញផ្សព្វផ្សាយផ្សេងៗទៀតដែលមានណាមួយ ។ ថ្លៃសេវា និងកម្រៃផ្សេងៗ ដែលបានកែប្រែឡើងវិញ ភ្ជាប់ជាកាតព្វកិច្ចរបស់ លោកអ្នកនៅថ្ងៃដែលបានកែប្រែឡើងវិញ នៅក្នុងឧបសម្ព័ន្ធ ឬតាមការជូនដំណឹង។

៨.២ ថ្លៃកម្រៃសេវាទាំងអស់ និងពន្ធផ្សេងៗ ប្រសិនបើមាននឹងត្រូវកាត់ចេញពីគណនីប័ណ្ណឥណទានរបស់លោកអ្នក នៅពេលដល់កំណត់សងនឹងអាចទូទាត់សង ហើយនឹងមិនអាចធ្វើការសងត្រឡប់ជូនវិញទេ។

៨.៣ ពន្ធ ឬ ពន្ធអាករណាមួយដែលបានកំណត់ដោយច្បាប់ ឬទៅលើថ្លៃសេវា កម្រៃផ្សេងៗ ដែលកាត់ដោយធនាគារពីលោកអ្នក យោងតាមអត្រាប្តូរប្រាក់ជាក់ស្តែង។

## ៩. ការកាន់កាប់ប័ណ្ណឥណទាន

៩.១ ប័ណ្ណឥណទាននេះជាកម្មសិទ្ធិរបស់ធនាគារគ្រប់ពេលវេលា។ លោកអ្នកមិនមែនជាអ្នកកាន់កាប់ ឬ អាចគ្រប់គ្រងប័ណ្ណឥណទានក្នុងគោលបំណងណាមួយ ដែលធនាគារមិនអនុញ្ញាតនោះទេ។

៩.២

ក) លោកអ្នកត្រូវប្រុងប្រយ័ត្នពីការលួច បាត់បង់ ឬការប្រើប្រាស់ប័ណ្ណឥណទានរបស់លោកអ្នកដោយគ្មាន ការអនុញ្ញាត។ ប្រសិនបើមានករណីបែបនេះកើតឡើងលោកអ្នកត្រូវតែជូនដំណឹងដល់ធនាគារភ្លាមៗ តាមរយៈអ៊ីមែល ឬទូរស័ព្ទ (ប្រសិនបើ តាមរយៈទូរស័ព្ទ ឬ ទៅសមាជិកណាម្នាក់នៃ Visa ឬ AMEX អន្តរជាតិ ត្រូវជូនដំណឹងលាយលក្ខណ៍អក្សរមកធនាគារអំពីព្រឹត្តិការណ៍នេះ)។ លោកអ្នកត្រូវរាយការណ៍ទៅអាជ្ញាធរ ដែនដីឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

ខ) លោកអ្នកនឹងទទួលខុសត្រូវចំពោះប្រតិបត្តិការ ដែលបានកើតឡើងដោយមិនមានការអនុញ្ញាត ដែលតម្រូវឲ្យមានការបង្ហាញនូវប័ណ្ណឥណទាន និងការបញ្ជាក់លេខសម្ងាត់ ឬហត្ថលេខា ប្រសិនបើលោកអ្នក៖

(i) បានប្រព្រឹត្តអំពើក្លែងបន្លំ

(ii) យឺតយ៉ាវក្នុងការជូនដំណឹងដល់ធនាគារនៅពេលបាត់ ឬត្រូវបានលួច ឬការប្រើប្រាស់ប័ណ្ណឥណទានដោយមិនមានការអនុញ្ញាត

(iii) ដោយបង្ហាញលេខសម្ងាត់ ឬអនុញ្ញាតឲ្យតតិយជនប្រើប្រាស់ប័ណ្ណឥណទាន

(iv) បានកត់ត្រាលេខសម្ងាត់នៅលើប័ណ្ណឥណទាន ឬរក្សាទុកនៅកន្លែងផ្សេងទៀតជាមួយគ្នា ឬ

(v) ដោយធ្វេសប្រហែស(១) ទុកប័ណ្ណឥណទានចោល ឬ (២) ផ្តល់លេខសម្ងាត់ឲ្យតតិយជន។

៩.៣ តាមសំណើរបស់លោកអ្នក ធនាគារអាចធ្វើប័ណ្ណឥណទានថ្មីបានក្នុងតម្លៃដប់ប្រាំ (១៥) ដុល្លារអាមេរិកសម្រាប់ប័ណ្ណឥណទានថ្មីក្រោមគណនីប័ណ្ណឥណទានរបស់លោកអ្នក ប្រសិនបើការធ្វើប័ណ្ណថ្មីដោយសារ៖

ក) ការបាត់ ឬលួច ឬបាក់បែក

ខ) ការបង្ហាញដោយគ្មានការអនុញ្ញាតនៃព័ត៌មានលម្អិតទាក់ទងនឹងប័ណ្ណឥណទានទៅតតិយជន ឬ

គ) លោកអ្នកស្នើសុំផ្លាស់ប្តូរយកលេខប័ណ្ណឥណទាន។

៩.៤ លោកអ្នកត្រូវប្រគល់ប័ណ្ណឥណទាន ដែលកាត់ពាក់កណ្តាលជូនធនាគារវិញភ្លាមៗនៅពេលដែល៖

ក) ប័ណ្ណឥណទានផុតកំណត់ ឬ

ខ) តាមការទាមទាររបស់ធនាគារ ឬ

គ) ការរកឃើញប័ណ្ណឥណទាន បន្ទាប់ពីលោកអ្នកបានជូនដំណឹងមកធនាគារអំពីការបាត់ (ក្នុងករណីនេះលោកអ្នកនឹងមិនត្រូវព្យាយាមប្រើប្រាស់ប័ណ្ណឥណទានទៀតឡើយ)។

## ១០. ប័ណ្ណ និងលេខសម្ងាត់សុវត្ថិភាព

១០.១

ក) លោកអ្នកត្រូវតែធានាថារាល់ព័ត៌មាន ដែលបានផ្តល់ជូនធនាគារ គឺត្រឹមត្រូវ និងមានបច្ចុប្បន្នភាព។

ខ) លោកអ្នកត្រូវតែធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់លោកអ្នក តាមសំណើរបស់ធនាគារក្នុងគោលបំណងកត់ត្រា ផ្ទៀងផ្ទាត់ និង រក្សាសុវត្ថិភាព។

១០.២

ក) លោកអ្នកត្រូវធានាថាលេខសម្ងាត់ ត្រូវបានរក្សាទុកជាសម្ងាត់ និងរក្សាសុវត្ថិភាពយ៉ាងម៉ត់ចត់គ្រប់ពេល ហើយនឹងមិនត្រូវបង្ហាញដល់តតិយជនណាមួយឡើយ។ ដើម្បីការពារលោកអ្នកត្រូវតែះ

- (i) លុបសារជូនដំណឹងបន្ទាប់ពីទទួលបានលេខសម្ងាត់ណាមួយឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន
- (ii) ធានាថាលេខសម្ងាត់ត្រូវបានរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព និងមិនរក្សាទុកក្នុងកំណត់ត្រាដោយការសរសេរលេខសម្ងាត់នៅកន្លែងណាមួយ ឬនៅជិតប័ណ្ណឥណទាន។
- (iii) មិនអនុញ្ញាតឲ្យនរណាម្នាក់ផ្សេងទៀតឃើញ លេខសម្ងាត់របស់លោកអ្នកក្នុងពេលវាយបញ្ចូលលេខសម្ងាត់ឡើយ។
- (iv) មិនត្រូវប្រើប្រាស់លេខសម្ងាត់ដោយធ្វេសប្រហែស ដែលនាំឲ្យមានប្រតិបត្តិការដែលមិនសមស្រប អាចធ្វើឡើងដោយតតិយជន។
- (v) ជៀសវាងការប្រើប្រាស់លេខដែលងាយស្រួលសម្រាប់កំណត់ជាលេខសម្ងាត់ (ដូចជា ថ្ងៃខែឆ្នាំកំណើត ឬ លេខអត្តសញ្ញាណប័ណ្ណ ឬលេខទូរស័ព្ទដៃ)។
- (vi) ធ្វើការជូនដំណឹងដល់ធនាគារភ្លាម នៅពេលដឹងថាលេខសម្ងាត់ត្រូវបានគេលួច តាមរបៀបណាមួយ (ឧទាហរណ៍ ប្រសិនបើលោកអ្នកទទួលបានសារខ្លី ឬ ការជូនដំណឹងអំពីប្រតិបត្តិការដែលទាក់ទងទៅនឹងប្រតិបត្តិការដោយមិនមានការអនុញ្ញាត)។
- (vii) ប្រើប្រាស់ប័ណ្ណឥណទានដោយទទួលខុសត្រូវនិងមិនត្រូវប្រើប្រាស់ចំពោះសកម្មភាពណាមួយ ដែលខុសច្បាប់ និង
- (viii) ពិនិត្យមើលរបាយការណ៍គណនីប័ណ្ណប្រចាំខែនីមួយៗ ដោយយកចិត្តទុកដាក់ និង រាយការណ៍ពីភាពមិនប្រក្រតីភ្លាមៗ មកធនាគារ។

## ១១. ប័ណ្ណឥណទានរង

១១.១ ប្រសិនបើលោកអ្នក ជាម្ចាស់ប័ណ្ណឥណទានមេ ធនាគារអាចផ្តល់ប័ណ្ណឥណទានរងទៅកាន់បុគ្គលម្នាក់ទៀត ដែលលោកអ្នកអនុញ្ញាតតាមការស្នើសុំរបស់លោកអ្នកនិងតាមការសម្រេចរបស់ធនាគារ។ ប័ណ្ណឥណទានរង នេះនឹងក្លាយជាផ្នែកនៃប័ណ្ណឥណទានរបស់លោកអ្នក ហើយរាល់ការចំណាយ ដែលកើតឡើងក្រោម ប័ណ្ណឥណទានរងនឹងត្រូវកាត់ចេញពីគណនីប័ណ្ណឥណទានរបស់លោកអ្នក។

១១.២ ខ និងលក្ខខណ្ឌទាំងនេះនឹងអនុវត្តដូចគ្នាចំពោះប័ណ្ណឥណទានរងទាំងអស់។ ដោយការប្រើប្រាស់ប័ណ្ណឥណទានរង ម្ចាស់ប័ណ្ណឥណទានរងនឹងត្រូវបានចាត់ទុកថាបានយល់ព្រមចំពោះ ខ និងលក្ខខណ្ឌទាំងនេះ បានដាក់លើម្ចាស់ប័ណ្ណឥណទានឲ្យអនុវត្ត។ ប្រសិនបើលោកអ្នកជាម្ចាស់ប័ណ្ណឥណទានមេ លោកអ្នកនឹងត្រូវទទួលខុសត្រូវះ

ក) ចំពោះរាល់សកម្មភាពរបស់ម្ចាស់ប័ណ្ណឥណទានរង និងរាល់ចំណាយទាំងអស់ (រួមមានថ្លៃសេវា ការចំណាយ និងកម្រៃផ្សេងៗ) ដែលកើតចេញពីម្ចាស់ប័ណ្ណឥណទានរងរបស់លោកអ្នក និង

ខ) ត្រូវធានាថាម្ចាស់ប័ណ្ណឥណទានរងរបស់លោកអ្នកគោរពតាម ខ និងលក្ខខណ្ឌទាំងនេះ (ដូចដែលបានដាក់ឲ្យម្ចាស់ប័ណ្ណអនុវត្ត) និងបំពេញតាមកាតព្វកិច្ចរបស់គាត់។ តាមសេចក្តីយោងទាំងអស់ក្នុង ខ នៃ "ប័ណ្ណឥណទាន" ចំពោះបំណុលឡើងដោយលោកអ្នក ពាក់ព័ន្ធនឹងការប្រើប្រាស់ប័ណ្ណឥណទាននឹងត្រូវបានយល់ព្រមក្នុងការអនុវត្ត។

១១.៣ ទោះបីជាយ៉ាងណាក៏ដោយម្ចាស់ប័ណ្ណឥណទានរងនឹងទទួលខុសត្រូវ ចំពោះការចំណាយទាំងអស់ដែលធ្វើឡើងដោយម្ចាស់ប័ណ្ណឥណទានរងផ្ទាល់ផងដែរ។

១១.៤ ធនាគារធ្វើការសម្រេចក្នុងការយល់ព្រមចំពោះសំណើរណាមួយ ដែលធ្វើឡើងដោយលោកអ្នកដើម្បីឲ្យប័ណ្ណឥណទានរងអាចប្រើប្រាស់គណនីចរន្ត ឬ គណនីសន្សំរបស់លោកអ្នក ឬ ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM/SRM) បាន។

១១.៥ លោកអ្នកអាចធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរដើម្បីបិទប័ណ្ណឥណទានរងណាមួយ។ ប្រសិនបើលោកអ្នកធ្វើដូច្នេះ ប័ណ្ណឥណទានរងត្រូវតែកាត់ពាក់កណ្តាលហើយផ្នែកដែលបានកាត់ពាក់កណ្តាលនោះ ត្រូវប្រគល់ជូនធនាគារវិញ។ ការបិទនេះនឹងមិនប៉ះពាល់ដល់សិទ្ធិ ឬ កាតព្វកិច្ចណាមួយ របស់ធនាគារ ឬ លោកអ្នកឡើយ។

## ១២. កំហុស

១២.១ ករណីនីមួយៗខាងក្រោមនេះ គឺជាព្រឹត្តិការណ៍នៃកំហុស៖

(ក) ប្រសិនបើលោកអ្នកយឺតយ៉ាវមិនបានបង់ប្រាក់ដែលត្រូវបង់នៅក្រោម ខ និងលក្ខខណ្ឌទាំងនេះទៅតាមពេលដែលកំណត់ ឬ

(ខ) ប្រសិនបើលោកអ្នកប្រើប្រាស់លើសចំនួនកម្រិតឥណទាន ឬ

(គ) ប្រសិនបើលោកអ្នក ឬម្ចាស់ប័ណ្ណឥណទានរងណាមួយ ប្រតិបត្តិខុសពីលក្ខខណ្ឌ នៃកិច្ចព្រមព្រៀងនេះ ឬ

(ឃ) ប្រសិនបើមានពាក្យបណ្តឹងប្រឆាំងនឹងលោកអ្នក ទាមទារឲ្យលោកអ្នកស្ថិតនៅក្រោមស្ថានភាពក្ស័យធន ឬប្រហាក់ប្រហែល (មិនថានៅកន្លែងណាទេ) ហើយបើមិនមានដំណោះស្រាយជាក់លាក់ណាមួយក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ឬ

(ង) ប្រសិនបើមានសេចក្តីសម្រេចតុលាការណាមួយពាក់ព័ន្ធនឹងថវិការ ដែលត្រូវធ្វើឡើងប្រឆាំងនឹងលោកអ្នក ហើយមិនត្រូវបានដោះស្រាយពេញលេញក្នុងរយៈពេលសាមសិប (៣០)ថ្ងៃ ឬ

(ច) ប្រសិនបើធនាគាររកឃើញថា ស្ថានភាពហិរញ្ញវត្ថុ ឬលទ្ធភាពទូទាត់របស់លោកអ្នក ជួបបញ្ហាដែលមិនអាចអនុវត្តតាម ខ និងលក្ខខណ្ឌនេះ ឬ

(ឆ) ប្រសិនបើប័ណ្ណឥណទានមេ ឬប័ណ្ណឥណទានរងណាមួយត្រូវបានប្រើដើម្បីធ្វើការទូទាត់ទំនិញមិនស្របច្បាប់ ឬធ្វើប្រតិបត្តិការដែលផ្ទុយពីច្បាប់ណាមួយ ឬ

(ជ) ប្រសិនបើប័ណ្ណឥណទានមេ ឬប័ណ្ណឥណទានរងណាមួយប្រើប្រាស់ដើម្បីទិញទំនិញ ឬសេវាកម្មដែលមិនមែនជាការប្រើប្រាស់ផ្ទាល់ខ្លួនក្នុងគោលបំណង ជួញដូរ ឬត្រូវបានទិញសម្រាប់អាជីវកម្ម ឬជំនួញ ឬកេងប្រវ័ញ្ច។

TERMS & CONDITIONS

Maybank

(ឈ) ក្នុងករណីប័ណ្ណឥណទានមេ ឬប័ណ្ណឥណទានរងណាមួយ នៅពេលដែលលទ្ធភាពទូទាត់សងរបស់លោកអ្នក មានការធ្លាក់ចុះខ្លាំង រួមទាំងការធ្លាក់ចុះនៃចំណាត់ថ្នាក់ឥណទាន ស្ថានភាពហិរញ្ញវត្ថុមិនល្អ ការបំពានកិច្ចសន្យាផ្សេងៗណាមួយ ការផ្លាស់ប្តូរអវិជ្ជមានក្នុងប្រតិបត្តិការអាជីវកម្ម ឬសញ្ញាណាមួយដែលធនាគារយល់ថាមានហានិភ័យឥណទានខ្ពស់។

១២.២ ប្រសិនបើមានព្រឹត្តិការណ៍ណាមួយ ឬច្រើនខាងលើកើតឡើង ធនាគារមានសិទ្ធិសម្រេច ៖

(ក) លុបចោល ឬបដិសេធមិនចេញប័ណ្ណឥណទានមេ និង/ឬ ប័ណ្ណឥណទានរងសារជាថ្មីទេ ឬ

(ខ) ផ្អាក ឬកំណត់ការប្រើប្រាស់ប័ណ្ណឥណទានមេ និង/ឬ ប័ណ្ណឥណទានរងរបស់លោកអ្នកណាមួយ។ នៅក្នុងករណីនេះ ប្រាក់ដែលជំពាក់ទាំងអស់ក្រោមគណនីប័ណ្ណឥណទានរបស់លោកអ្នកនឹងត្រូវដល់ពេលកំណត់សងភ្លាមៗ ហើយលោកអ្នកត្រូវទូទាត់តាមការទាមទាររបស់ធនាគារ។

១២.៣ លោកអ្នកយល់ព្រមថា ប្រសិនបើប័ណ្ណឥណទានរបស់លោកអ្នកត្រូវបានបិទ ឬផ្អាក ធនាគារអាចដាក់ឈ្មោះរបស់លោកអ្នកចូលក្នុងបញ្ជីបិទគណនីដែលអាចត្រូវបានចែកចាយទៅគ្រប់អាជីវករ និង/ឬ នៅតាមបញ្ជរឲ្យដកជាសាច់ប្រាក់និងសាខាទាំងអស់របស់ធនាគារ និងសាខាជាដៃគូរបស់ធនាគារ។

## ១៣. ការមិនទទួលខុសត្រូវ

១៣.១ ធនាគារ មិនទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតណាមួយរបស់លោកអ្នក ឬម្ចាស់ប័ណ្ណឥណទានរង ដោយសារការមិនព្រមធ្វើប័ណ្ណថ្មីឡើងវិញ ឬលុបចោលប័ណ្ណឥណទានមេ ឬប័ណ្ណឥណទានរង ឬការផ្អាក ឬការកំណត់សិទ្ធិប្រើប្រាស់ ប័ណ្ណឥណទានមេ ឬប័ណ្ណឥណទានរងណាមួយ។

១៣.២ ធនាគារមិនទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតចំពោះលោកអ្នក ដែលបានបង្កដោយអាជីវករ ឬបញ្ជរដកប្រាក់។ លោកអ្នកគួរតែដោះស្រាយរាល់ការតវ៉ា ឬ ជម្លោះជាមួយទីតាំងអាជីវករ ឬបញ្ជរដកប្រាក់ដោយផ្ទាល់ជាមួយអង្គភាពនោះ។ ទោះបីជាមានពាក្យបណ្តឹង ឬជម្លោះកើតឡើង លោកអ្នកត្រូវតែធ្វើការទូទាត់រាល់ការចំណាយដល់ធនាគារក្រោម ខ និងលក្ខខណ្ឌ ទាំងនេះ។

១៣.៣ លោកអ្នកត្រូវទទួលខុសត្រូវរាល់ការចំណាយទាំងអស់ដែលបានកើតឡើង តាមរយៈប្រតិបត្តិការប័ណ្ណឥណទានទាំងអស់បានធ្វើយ៉ាងត្រឹមត្រូវ ឬចាត់ទុកថាបានអនុញ្ញាតពីលោកអ្នក។ ប្រការនេះមិនប៉ះពាល់ដល់ការទទួលខុសត្រូវរបស់លោកអ្នក នៅក្រោម ប្រការ ៩.២ នៃ ខ និងលក្ខខណ្ឌនេះទេ។

## ១៤. ប្រតិបត្តិការមិនមែនជាប្រាក់ដុល្លារអាមេរិក

១៤.១ លោកអ្នកអាចប្រើប្រាស់ប័ណ្ណឥណទានជាមួយប្រតិបត្តិការមិនមែនជាប្រាក់ដុល្លារអាមេរិកនៅទីតាំងអាជីវករ និង/ឬ បញ្ជរដកប្រាក់។

១៤.២ លោកអ្នកអាចប្រើប្រាស់ប័ណ្ណឥណទាន សម្រាប់ការដកប្រាក់តាមរយៈម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATMs) ដែលបានអនុញ្ញាតដោយធនាគារ និង/ឬ អាជីវករដៃគូរបស់ក្រុមហ៊ុនវីសាអន្តរជាតិ ឬ ក្រុមហ៊ុនអាមេរិកខេនអ៊ិចប្រេស្ស (AMEX) អន្តរជាតិ (អាស្រ័យតាមប្រភេទប័ណ្ណឥណទានរបស់លោកអ្នក)។

១៤.៣ លោកអ្នកអនុញ្ញាតឲ្យធនាគារអនុវត្តគ្រប់ជំហ៊ានទាំងអស់ដែលតម្រូវដោយធនាគារ ដើម្បីអនុលោមតាមនីតិវិធីរដ្ឋបាល និង បទប្បញ្ញត្តិស្តីពីអត្រាប្តូរប្រាក់បរទេសដែលចេញដោយធនាគារជាតិនៃកម្ពុជា ឬក្រុមហ៊ុន

វីសាអន្តរជាតិ ឬ ក្រុមហ៊ុនអាមេរិកខេនអ៊ិចប្រេស្ស (AMEX) អន្តរជាតិ ទាក់ទងនឹងប្រតិបត្តិការរូបិយប័ណ្ណ។ ការអនុញ្ញាតនេះនឹងបន្តភ្ជាប់ជាកាតព្វកិច្ចលោកអ្នកគ្រប់ពេលវេលានឹងមិនត្រូវបានដកចេញឡើយ។

១៤.៤ ប្រតិបត្តិការដែលធ្វើឡើងមិនមែនជាប្រាក់ដុល្លារអាមេរិកនឹងត្រូវបានប្តូរទៅជាដុល្លារអាមេរិកនៅថ្ងៃដែលប្រតិបត្តិការត្រូវបាន ទទួល និង/ឬ ដំណើរការដោយធនាគារ។ ចំនួនទឹកប្រាក់ដែលបានប្តូរនឹងត្រូវបានបង្ហាញនៅលើរបាយការណ៍គណនីរបស់លោកអ្នក។ អត្រាប្តូរប្រាក់ដែលប្រើសម្រាប់ការផ្លាស់ប្តូរនេះអាចខុសគ្នាពីអត្រាប្តូរប្រាក់នៅថ្ងៃធ្វើប្រតិបត្តិការដោយសារតែការប្រែប្រួលអត្រាប្តូរប្រាក់លើទីផ្សារ។ អត្រាប្តូរប្រាក់ដែលបានប្រើនឹងបង្ហាញដោយរួមបញ្ចូលទាំង ២% ឬអត្រាដែលបានកំណត់ដោយធនាគារនៅពេលណាមួយ។

## ១៥. សំណងខូចខាត

១៥.១ លោកអ្នកយល់ព្រមផ្តល់សំណងឲ្យធនាគារ និងធានាអះអាងផ្តល់សំណងដល់ធនាគារ លើបំណុល ការបាត់បង់ ការខូចខាត ការចំណាយផ្សេងៗ (រួមទាំងការចំណាយសេវាផ្នែកច្បាប់តាមការព្រមព្រៀងរវាងមេធាវី និងអតិថិជនជាមូលដ្ឋាន) ឬធនាគារអាចត្រូវចំណាយដើម្បីចុះកិច្ចព្រមព្រៀង អនុវត្តកាតព្វកិច្ច ឬ ការអនុវត្តសិទ្ធិរបស់ធនាគារនៅក្រោមលក្ខខណ្ឌទាំងនេះ។

១៥.២ លោកអ្នកនឹងបង់ថ្លៃជូនធនាគារលើការចំណាយផ្នែកច្បាប់ទាំងអស់ (ការចំណាយសេវាផ្នែកច្បាប់តាមការព្រមព្រៀងរវាងមេធាវីនិងអតិថិជនជាមូលដ្ឋាន) និងការចំណាយទាំងអស់ ដែលធ្វើឡើងដោយធនាគារក្នុងការអនុវត្តសិទ្ធិរបស់ធនាគារនៅក្រោមលក្ខខណ្ឌទាំងនេះ។

១៥.៣ សំណងការខូចខាតនឹងបន្តសុពលភាពនិងមានប្រសិទ្ធភាព ទោះបីជាមានការលុបចោល ឬការបញ្ចប់ប័ណ្ណឥណទានក៏ដោយ។

## ១៦. ការបិទប័ណ្ណឥណទានមេ និងប័ណ្ណឥណទានរង

១៦.១ លោកអ្នកអាចបញ្ចប់លក្ខខណ្ឌទាំងនេះនៅពេលណាមួយដោយៈ

ក) ជូនដំណឹងដល់ធនាគារជាលាយលក្ខណ៍អក្សរ និង

ខ) ប្រគល់ប័ណ្ណឥណទានមេ និងប័ណ្ណឥណទានរងទាំងអស់ ដែលបានកាត់ពាក់កណ្តាលជូនធនាគារវិញ។ ធនាគារនឹង មិនសងត្រឡប់វិញនូវថ្លៃប័ណ្ណប្រចាំឆ្នាំឬសងត្រឡប់នូវចំនួនណាមួយ ក្នុងករណីបិទប័ណ្ណឥណទាន។

១៦.២ ប្រសិនបើលោកអ្នកចង់បិទប័ណ្ណឥណទានរង ដោយមិនចាំបាច់បិទប័ណ្ណឥណទានមេ លោកអ្នកត្រូវតែៈ

ក) ជូនដំណឹងដល់ធនាគារជាលាយលក្ខណ៍អក្សរ និង

ខ) ប្រគល់ប័ណ្ណឥណទានរង ជូនធនាគារវិញ ដែលបានកាត់ជាពាក់កណ្តាល។ ធនាគារនឹងមិនទទួលខុសត្រូវចំពោះការខាតបង់ណាមួយ ដែលបណ្តាលមកពីការប្រើប្រាស់ឥណទានរង ដោយម្ចាស់ប័ណ្ណឥណទានរង និង/ឬ តតិយជនណាមួយឡើយ។

១៦.៣ ធនាគារអាចបញ្ចប់លក្ខខណ្ឌទាំងនេះនៅពេលណាក៏បាន តាមឆន្ទានុសិទ្ធិរបស់ធនាគារ ដោយមិនត្រូវបានតម្រូវឲ្យផ្តល់ហេតុផលណាមួយឡើយ។

១៦.៤ ការបញ្ចប់លក្ខខណ្ឌនេះនឹងមិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់លោកអ្នក ឬធនាគារដែលបានរក្សាទុកឡើយ ។

## ១៧. រង្វាន់

១៧.១ ក្នុងនាមជាម្ចាស់ប័ណ្ណមេ លោកអ្នកមានសិទ្ធិទទួលរង្វាន់លើការទិញទំនិញ និងសេវាកម្មដែលធ្វើឡើងដោយប្រើប្រាស់ប័ណ្ណឥណទានរបស់លោកអ្នក ក្នុងគោលបំណងនៃការប្រើប្រាស់ផ្ទាល់ខ្លួនតែប៉ុណ្ណោះ និងមិនមែនសម្រាប់គោលបំណងអាជីវកម្ម ឬសារជីវកម្មទេ។ ធនាគារនឹងផ្តល់រង្វាន់តែនៅពេល ការទិញរបស់លោកអ្នកស្ថិតក្នុងប្រភេទណាមួយដែលធនាគារកំណត់ និងបានអនុញ្ញាតប៉ុណ្ណោះ។

១៧.២ ធនាគាររក្សាសិទ្ធិក្នុងការមិនផ្តល់រង្វាន់ណាមួយដល់លោកអ្នក ដោយគ្មាន ការទាមទារឲ្យផ្តល់ហេតុផលណាមួយដល់លោកអ្នកឡើយ ប្រសិនបើធនាគារមើលឃើញថាលោកអ្នកមាន
ឬមិនមានសិទ្ធិទទួលបានរង្វាន់ជាការសម្រេចចិត្តចុងក្រោយរបស់ធនាគារ នឹងភ្ជាប់ជាកាតព្វកិច្ចអនុវត្តចំពោះលោកអ្នក។

១៧.៣ រង្វាន់ដែលបានសន្សំដោយលោកអ្នកក្នុងការប្រើប្រាស់ប័ណ្ណឥណទាននឹងត្រូវលុបចោលភ្លាមៗ នៅពេលប័ណ្ណឥណទានបិទ ឬបញ្ចប់លក្ខខណ្ឌទាំងនេះ។

១៧.៤ ធនាគារមានសិទ្ធិទាមទារសងនូវតម្លៃពេញលេញនៃរង្វាន់ណាមួយ ដែលបានផ្តល់ជូននឹងទទួលយកដោយលោកអ្នក ដែលលោកអ្នកមិនមានសិទ្ធិត្រូវទទួលនៅក្រោមលក្ខខណ្ឌទាំងនេះព្រមទាំងតម្លៃ និងការចំណាយដែលពាក់ព័ន្ធផ្សេងទៀត។

## ១៨. ការបង្ហាញព័ត៌មាន និងទិន្នន័យរបស់អតិថិជន

១៨.១ រក្សាទុកសម្រាប់គោលបំណងធ្វើទីផ្សារ និង/ឬ ការលក់ផ្សេងៗទៀត ក្នុងនោះច្បាប់ និង/ឬ បទប្បញ្ញត្តិ លើការ ″ទទួលយក″ ការទាមទារនឹងត្រូវបានអនុលោមតាមលោកអ្នកអនុញ្ញាតឲ្យធនាគារប្រមូលដំណើរការ ថែទាំ រក្សាទុក និងរក្សាទិន្នន័យផ្ទាល់ខ្លួនរបស់លោកអ្នក ដើម្បីបង្ហាញ និងផ្ទេរទៅអង្គភាពផ្សេងទៀតនៅក្នុង សម្ព័ន្ធធនាគារ (រួមមានសាខាក្នុងស្រុក និងក្រៅស្រុក) និងភ្នាក់ងាររបស់យើង និងអ្នកតំណាងផ្តល់សេវាកម្ម និង/ឬ ចូលរួមក្នុងគោលបំណងនៃកិច្ចសន្យានេះក្នុង និងក្រៅប្រទេសកម្ពុជា។

១៨.២ លោកអ្នកត្រូវអនុញ្ញាតឲ្យធនាគារធ្វើការពិនិត្យឥណទាន (CBC) និងផ្ទៀងផ្ទាត់ព័ត៌មានដែលផ្តល់ដោយលោកអ្នកដល់ធនាគារដែលទាក់ទងទៅនឹងលក្ខខណ្ឌទាំងនេះ (រួមទាំងនៅក្នុងពាក្យស្នើសុំប័ណ្ណឥណទាន) ជាមួយក្រុមហ៊ុនផ្តល់ព័ត៌មានហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធផ្សេងទៀត។

១៨.៣ លោកអ្នកអនុញ្ញាតឲ្យធនាគារបង្ហាញព័ត៌មានលម្អិតទាក់ទងនឹងគណនីប័ណ្ណឥណទានរបស់លោកអ្នក និងគណនីផ្សេងទៀតដែលមានជាមួយធនាគារ និងទំនាក់ទំនងរបស់លោកអ្នកជាមួយធនាគារ (រួមទាំងប្រតិបត្តិការប័ណ្ណឥណទាន និងសមតុល្យឥណទានរបស់លោកអ្នក) ទៅ៖

(ក) រាជរដ្ឋាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច ឬភ្នាក់ងារដទៃទៀតនៅក្នុងប្រទេសកម្ពុជា និងកន្លែងផ្សេងទៀត រួមមាន ធនាគារជាតិនៃកម្ពុជា (NBC) និងក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិល ធីឌី (CBC)

(ខ) សមាជិកសម្ព័ន្ធរបស់ធនាគារមេយប៊ែង

(គ) ដៃគូណាមួយដែលផ្តល់សេវាកម្មដល់ធនាគារ

(ឃ) ភ្នាក់ងាររបស់ធនាគារ (រួមទាំងភ្នាក់ងារតំណាង ក្នុងគោលបំណងប្រមូលមកវិញនូវចំនួនប្រាក់ដែលមិនទាន់បានបង់ និងការបង់ប្រាក់មកធនាគារ) ទីប្រឹក្សា និង ទីប្រឹក្សាដែលមានវិជ្ជាជីវៈបានតែងតាំងឡើងក្នុងគោលបំណងដូចគ្នា

(ង) អ្នកទទួលបន្ទុករបស់ធនាគារ ឬសមាជិកណាមួយដែលស្ថិតក្នុងសម្ព័ន្ធរបស់ធនាគារ
(ច) មន្ត្រីនគរបាល ឬមន្ត្រីស៊ើបអង្កេត ដែលកំពុងធ្វើការស៊ើបអង្កេតណាមួយ និង
(ឆ) បុគ្គលដែលត្រូវបានអនុញ្ញាតឲ្យទទួលដឹងលឺ ឬតម្រូវដោយច្បាប់ បទប្បញ្ញត្តិ ឬសេចក្តីបង្គាប់ ឬសំណើរបស់រាជរដ្ឋាភិបាល។

១៨.៤ អនុលោមតាមបទប្បញ្ញត្តិ ឬគោលការណ៍ណែនាំដែលអាចអនុវត្តបាន (រួមទាំងការអនុលោមតាមតម្រូវការដែលចាំបាច់ណាមួយ "ទទួលយក" សម្រាប់គោលបំណង នៃសកម្មភាពទីផ្សារ ឬការលក់ផ្សេងៗទៀត) ធនាគារអាចប្រើផ្នែកណាមួយនៃព័ត៌មានរបស់លោកអ្នកដែលបានប្រមូលដោយធនាគារក្នុងគោលបំណងដូចរៀបរាប់ខាងលើដែលបានកំណត់ដោយធនាគារ។

១៨.៥ លោកអ្នកអនុញ្ញាតឲ្យធនាគារប្រើប្រាស់ ការបង្ហាញ ការលាតត្រដាង ឬបង្ហាញព័ត៌មានណាមួយទាក់ទង នឹងកិច្ចការរបស់លោកអ្នក ឬគណនីរបស់លោកអ្នកជាមួយធនាគារ (រួមទាំងគណនីប័ណ្ណឥណទាន) ក្នុងគោលបំណង ឬពាក់ព័ន្ធទៅនឹងនីតិវិធីណាមួយសម្រាប់ការប្រមូលមកវិញនូវចំនួនទឹកប្រាក់ដែលមិនបានបង់ ឬ ការអនុវត្តសិទ្ធិរបស់ធនាគារនៅក្រោមលក្ខខណ្ឌទាំងនេះ។

១៨.៦ លោកអ្នកធានាអះអាងថាព័ត៌មានទាំងអស់ (ផ្ទាល់ខ្លួន ឬផ្សេងទៀត) ដែលផ្តល់ដោយលោកអ្នកគឺពេញលេញ និងត្រឹមត្រូវ។ លោកអ្នកត្រូវតែជូនដំណឹងដល់ធនាគារភ្លាមៗអំពីការផ្លាស់ប្តូរព័ត៌មានរបស់លោកអ្នក ដើម្បីធានាថាទិន្នន័យនៅក្នុងកំណត់ត្រារបស់ធនាគារ គឺមានបច្ចុប្បន្នភាព។

## ១៩. ការតែងតាំងភ្នាក់ងារ

១៩.១ ធនាគារមានជម្រើស ក្នុងការចាត់តាំងតំណាងភ្នាក់ងារ តាមការសម្រេចរបស់ធនាគារ ហើយអនុញ្ញាតឲ្យពួកគេធ្វើសកម្មភាពជំនួសធនាគារក្នុងការអនុវត្តសិទ្ធិរបស់ធនាគារនៅក្រោមលក្ខខណ្ឌទាំងនេះ (រួមទាំងការប្រមូលមកវិញនូវចំនួនទឹកប្រាក់ដែលមិនបានបង់ និងចំនួនទឹកប្រាក់ដែលត្រូវបង់ដោយលោកអ្នក ជូនធនាគារ)។

## ២០. ច្បាប់ប្រឆាំងនឹងអំពើពុករលួយ ច្បាប់ប្រឆាំងនឹងការលាងលុយ និង ច្បាប់ដាក់ទណ្ឌកម្ម

២០.១ ច្បាប់ប្រឆាំងនឹងអំពើពុករលួយ៖

លោកអ្នក អះអាងនិងធានា មកធនាគារថាលោកអ្នកនឹងប្រើប្រាស់ប័ណ្ណឥណទាន និងប្រើប្រាស់គណនីប័ណ្ណឥណទាន អនុលោមតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ គោលការណ៍ និងបទប្បញ្ញត្តិ ដែលអាច អនុវត្តបានទាំងអស់។

២០.២ ច្បាប់ប្រឆាំងការលាងលុយ៖

ក) លោកអ្នកត្រូវធានាថា គ្មានប្រាក់ក្នុងគណនីណាមួយ ដែលផ្ញើចេញពីគណនីរបស់លោកអ្នកដែលមានជាមួយធនាគារ (រួមទាំងគណនីប័ណ្ណឥណទាន) តំណាង ឲ្យការធ្វើប្រតិបត្តិការទទួលប្រាក់ចំណេញ ឬ នឹងត្រូវប្រើប្រាស់ ដែលចាត់ទុកថាជាសកម្មភាពមិនត្រឹមត្រូវ ដូចបានកំណត់នៅក្នុងច្បាប់ប្រឆាំងការលាងលុយ ហិរញ្ញប្បទានប្រឆាំងភេរវកម្ម និងការធ្វើប្រតិបត្តិការទទួលប្រាក់ចំណេញនៃសកម្មភាពមិនស្រប ច្បាប់ឆ្នាំ២០០១ (AMLATFAPUAA) និងច្បាប់ព្រះរាជាណាចក្រ កម្ពុជា។

TERMS & CONDITIONS

Maybank

ខ) លោកអ្នកយល់ព្រមថា លោកអ្នកនឹងមិនប្រើប្រាស់ប័ណ្ណឥណទាន ឬធ្វើប្រតិបត្តិការលើគណនីប័ណ្ណឥណទាន ក្នុងកំឡុងពេលនៃលក្ខខណ្ឌទាំងនេះទៅកាន់៖

១) ការចូលរួម ដោយផ្ទាល់ ឬដោយប្រយោលក្នុងការធ្វើប្រតិបត្តិការ ដែលពាក់ព័ន្ធនឹងសកម្មភាពមិនស្របច្បាប់

២) បិទបាំង ឬក្លែង លក្ខណៈពិត នៃសកម្មភាពណាមួយដែលខុសច្បាប់ ឬ

៣) ប្រើប្រាស់ចំនួនទឹកប្រាក់ណាមួយពីគណនីរបស់លោកអ្នកសម្រាប់ការលាងលុយ ឬគោលបំណងខុសផ្សេងទៀត

២០.៣ ដាក់ទណ្ឌកម្ម៖

ក) ការទទួលស្គាល់របស់លោកអ្នក ទាំងប័ណ្ណលោកអ្នក ឬក៏ម្ចាស់ប័ណ្ណរងណាមួយ រួមទាំងសាច់ញាតិរបស់លោកអ្នកឬសាច់ញាតិរបស់ម្ចាស់ប័ណ្ណរងរបស់លោកអ្នកគឺជាបុគ្គលដែល (i) បច្ចុប្បន្នស្ថិតនៅក្រោមការដាក់ទណ្ឌកម្មណាមួយ ដែលគ្រប់គ្រង ឬអនុវត្តដោយប្រទេសម៉ាឡេស៊ី សហរដ្ឋអាមេរិក (OFAC) ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិសហភាពអឺរ៉ុប រដ្ឋាភិបាលចក្រភពអង់គ្លេស ឬអាជ្ញាធរដាក់ទណ្ឌកម្មពាក់ព័ន្ធផ្សេងទៀត (រួមគ្នា "ការដាក់ទណ្ឌកម្ម") ឬ (ii) មានទីតាំង ឬរស់នៅក្នុងប្រទេស ឬ តំបន់មួយដែលជាតំបន់ដាក់ទណ្ឌកម្ម។

ខ) ទាំងប័ណ្ណលោកអ្នក ឬក៏ម្ចាស់ប័ណ្ណរង មិនត្រូវធ្វើការដកប្រាក់តាមវិធីណាមួយ ដោយផ្ទាល់ ឬប្រយោល ឲ្យទៅបុគ្គលឬអង្គភាពណាមួយ ដែលនៅតាមតំបន់នៃការដាក់ទណ្ឌកម្មនោះទេ។

គ) លោកអ្នកត្រូវទទួលស្គាល់ថា ធនាគារមិនអាចដំណើរការប្រតិបត្តិការ ដែលរងផលប៉ះពាល់ ពាក់ព័ន្ធ ឬ ត្រូវបានសង្ស័យថាពាក់ព័ន្ធនឹងការរំលោភលើការការដាក់ទណ្ឌកម្ម ឬការទាមទារណាមួយ ដែលបានដាក់ដោយអាជ្ញាធរណាមួយដែលមានអំណាចលើធនាគារ ឬប្រតិបត្តិការដែលរងផលប៉ះពាល់នោះទេ។ ធនាគារនឹងមិនទទួលខុសត្រូវ ចំពោះការមិនជោគជ័យ ឬការពន្យារពេលក្នុងការដំណើរការប្រតិបត្តិការបែបនេះឡើយ។

## ២១. លក្ខខណ្ឌផ្សេងៗ

២១.១ សិទ្ធិក្នុងការទូទាត់ ការបូកបញ្ចូលសរុប និងសិទ្ធិដើម្បីដកប្រាក់៖

ក) ធនាគារអាចនឹងមិនផ្តល់ការជូនដំណឹងដល់លោកអ្នកជាមុន សម្រាប់ការទូទាត់ ឬ ផ្ទេរប្រាក់នូវចំនួនណាមួយ ចូលទៅគណនីឥណទានណាមួយរបស់លោកអ្នកដែលមានជាមួយធនាគារ (ទោះជាបានរៀបរាប់និងនៅកន្លែង ណាក៏ដោយ) សម្រាប់ការកាត់កង និង/ឬ ការទូទាត់នូវចំនួនទឹកប្រាក់ សរុបណាមួយដែលជំពាក់ ធនាគារនៅក្រោមកិច្ចព្រមព្រៀងនេះ។ ធនាគារមិនចាំបាច់ផ្តល់ហេតុផលណាមួយដល់លោកអ្នកក្នុងការអនុវត្តការទូទាត់ ឬការផ្ទេរបែបនេះទេ។

ខ) ធនាគារអាចនឹងមិនផ្តល់ការជូនដំណឹងដល់លោកអ្នក ជាមុន សម្រាប់ការទូទាត់ ឬផ្ទេរប្រាក់ណាមួយលើ ចំនួនឥណទាននៃគណនីប័ណ្ណឥណទានរបស់លោកអ្នក ដើម្បីធ្វើការកាត់កង និង/ឬ ការទូទាត់ចំនួន សរុបណាមួយ ដែលជំពាក់ធនាគារ ឬសេវាផ្សេងទៀតដែលបានផ្តល់ឲ្យលោកអ្នក (ដែលបានរៀបរាប់ និងនៅកន្លែងណាក៏ដោយ)។

Maybank

២១.២ ច្បាប់៖

កិច្ចព្រមព្រៀង និងប្រតិបត្តិការ ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះ គ្រប់គ្រងដោយច្បាប់ប្រទេសកម្ពុជា ដោយមិនគិតពី ទីកន្លែង ដែលប្រតិបត្តិការបានកើតមាននោះទេ។

២១.៣ ពេលវេលា៖

នៅទីកន្លែងណាក៏ដោយ លក្ខខណ្ឌទាំងនេះតម្រូវឲ្យមានសកម្មភាព ឬអ្វីដែលត្រូវធ្វើក្នុងរយៈពេលជាក់លាក់មួយ ឬភ្លាមៗ ឬកាន់តែឆាប់ដែលអាចធ្វើទៅបាន ការអនុលោមតាមតម្រូវការបែបនេះនឹងជាខ្លឹមសារនៃលក្ខខណ្ឌទាំងនេះ។

២១.៤ ការលើកលែង៖

ប្រសិនបើមានការខកខាន ឬការពន្យារពេលណាមួយកើតឡើងពីធនាគារក្នុងការអនុវត្ត សិទ្ធិ អំណាច ឬវិធីសាស្ត្រណាមួយរបស់ធនាគារនោះវានឹង មិនត្រូវបានសន្និដ្ឋានថាជាការលើកលែង ដែលធ្វើឲ្យខូចខាតសិទ្ធិ អំណាច ឬការដោះស្រាយបែបនេះទេ។

២១.៥ ការរក្សាសិទ្ធិ និងផលប្រយោជន៍៖

សិទ្ធិ និងផលប្រយោជន៍របស់ធនាគារ ស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះនឹងបន្តមានអនុភាព និងប្រសិទ្ធភាពពេញលេញបន្ទាប់ពីការលុបចោល ឬការផ្អាកប័ណ្ណឥណទានដោយធនាគារ។

២១.៦ ការកែប្រែ ខ និងលក្ខខណ្ឌ៖

ធនាគារអាចផ្លាស់ប្តូរ ខ និងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះនៅពេលដែលធនាគារធ្វើការសម្រេចចិត្តនៅពេលណាក៏បាន (រួមទាំងការបន្ថែមលក្ខខណ្ឌថ្មី ឬការដក ឬជំនួសលក្ខខណ្ឌដែលមានស្រាប់)។

ធនាគារ នឹងជូនដំណឹង ដប់ប្រាំ (១៥) ថ្ងៃជាមុន ដល់លោកអ្នក អំពីការផ្លាស់ ប្តូរណាមួយដែលបានធ្វើឡើង។ ធនាគារអាចជូនដំណឹង អំពីការផ្លាស់ប្តូរនេះ ដោយការចុះផ្សាយ នៅលើគេហទំព័រ (www.maybank2u.com.kh)។ ការផ្លាស់ប្តូរ ខ និងលក្ខខណ្ឌនឹងមានប្រសិទ្ធភាពនៅពេលផុតកំណត់នៃរយៈពេលដប់ប្រាំ (១៥) ថ្ងៃ។ លោកអ្នកគួរតែចូលទៅមើលគេហទំព័ររបស់ធនាគារឲ្យបានញឹកញាប់ដើម្បីប្រាកដថាលោកអ្នកដឹងពីការកែប្រែ ខ និងលក្ខខណ្ឌដែលនឹងជំនួសកិច្ចព្រមព្រៀងពីមុនទាំងអស់ ។ ប្រសិនបើលោកអ្នកមិនយល់ព្រមលើការផ្លាស់ប្តូរទេ លោកអ្នកត្រូវតែបញ្ឈប់ការប្រើប្រាស់ប័ណ្ណឥណទានភ្លាមៗ សូមទាក់ទងទៅកាន់តំណាងសេវាអតិថិជនរបស់ធនាគារដោយជូនដំណឹងដល់ពួកគេអំពីគោលបំណងរបស់លោកអ្នក និងចាត់វិធានការចាំបាច់ដើម្បីបញ្ចប់កិច្ចព្រមព្រៀងនេះភ្លាមៗ (ដូចដែលបានកំណត់នៅក្នុងប្រការ ១៦ ខាងលើ)។ ប្រសិនមិនធ្វើដូច្នេះទេ ឬប្រសិនបើលោកអ្នកប្រើប័ណ្ណឥណទាននៅថ្ងៃ ឬបន្ទាប់ពីកាលបរិច្ឆេទផ្លាស់ប្តូរមានប្រសិទ្ធ ភាពភ្លាមៗ ហើយលោកអ្នកត្រូវចាត់ទុកថាបានយល់ព្រមតាមការផ្លាស់ប្តូរនេះ។

២១.៧ បច្ចុប្បន្នភាពព័ត៌មាន និង អាសយដ្ឋាន៖

ធនាគារអាចផ្ញើលិខិត ទៅកាន់លោកអ្នកទៅកាន់អាសយដ្ឋាន ឬតាមរយៈអ៊ីម៉ែល ឬតាមរយៈសារអេឡិចត្រូនិចជូនលោកអ្នក ដូចដែលបានបញ្ជាក់នៅក្នុងទម្រង់ពាក្យស្នើសុំប័ណ្ណឥណទាន ឬ ផ្ញើតាមរយៈអាសយដ្ឋាន ឬអ៊ីម៉ែលឬលេខទូរស័ព្ទផ្សេងទៀត ដូចដែលលោកអ្នកបានជូនដំណឹងដល់ធនាគារជាលាយលក្ខណ៍អក្សរជាបន្តបន្ទាប់។ ការខកខានមួយរបស់លោកអ្នក ក្នុងការជូនដំណឹងដល់ធនាគារអំពី ការផ្លាស់ប្តូរអាសយដ្ឋាន ឬអ៊ីម៉ែល ឬលេខទូរស័ព្ទនឹងនៅតែប្រសិទ្ធភាពចំពោះព័ត៌មានណាមួយអំពីលោកអ្នក ឬសិទ្ធិ របស់ធនាគារនៅក្រោមកិច្ចព្រមព្រៀងនេះ។

២១.៨ សេវាកម្មនៃដំណើរការច្បាប់៖

លោកអ្នកយល់ព្រមឲ្យធនាគារចេញដីកា ឬដំណើរការច្បាប់ផ្សេងៗទៀត ទាក់ទងនឹងការទាមទារណាមួយ ដែលកើតចេញពី ឬពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងនេះ ទៅលោកអ្នកដោយផ្ញើឯកសារចម្លងនៃដំណើរការ តាមរយៈមន្ត្រីធនាគារ ឬមធ្យោបាយ ផ្សេងៗ ទៅកាន់អាសយដ្ឋានរបស់លោកអ្នកដូចដែលបានបញ្ជាក់នៅក្នុងទម្រង់ស្នើសុំប័ណ្ណឥណទាន ឬ អាសយដ្ឋានផ្សេងទៀត ដែលលោកអ្នកបានជូនដំណឹងដល់ធនាគារជាលាយលក្ខណ៍អក្សរ ជាបន្តបន្ទាប់។

២១.៩ វិញ្ញាបនបត្រនៃបំណុល៖

វិញ្ញាបនបត្រដែលបានចុះហត្ថលេខាដោយមន្ត្រីរបស់ធនាគារចំពោះទឹកប្រាក់ ដែលបានហួសកាលកំណត់បង់និងជំពាក់ធនាគារដោយលោកអ្នកនៅក្រោមកិច្ចព្រមព្រៀងនេះនឹងក្លាយជាកិច្ចព្រមព្រៀងចុងក្រោយ និងដាច់ស្រេច។

២១.១០ ទុព្វលភាពនៃកិច្ចព្រមព្រៀង៖

ប្រសិនបើចំណុចណាមួយក្នុងកិច្ចព្រមព្រៀងនេះ លែងមានសុពលភាព ឬមិនអាចអនុវត្តបាននឹងមិនប៉ះពាល់ធ្ងន់ធ្ងរដល់បំណងដែលបានបញ្ជាក់ ក្នុងលក្ខខណ្ឌទាំងនេះ ឬសុពលភាព ឬការអនុវត្ត នៃបទប្បញ្ញត្តិផ្សេងទៀត នៃលក្ខខណ្ឌទាំងនេះឡើយ។

២១.១១ ការសន្មត៖

កិច្ចព្រមព្រៀងនេះ បង្ហាញពីការព្រមព្រៀងរវាងលោកអ្នក និងធនាគារ ហើយលោកអ្នកឯកភាពថា មិនមាន ការផ្តល់ជូនតាមរយៈផ្ទាល់មាត់ ឬ ការសរសេរ ឬការបង្ហាញ ឬការបញ្ជាក់ ឬការគ្រប់គ្រងទំនាក់ទំនងរបស់ ធនាគារផ្សេងទៀតក្រៅពីលោកអ្នកដែលមាននៅក្នុង ខ និងលក្ខខណ្ឌទាំងនេះ។

២១.១២ កិច្ចព្រមព្រៀងជំនួស៖

រាល់ការព្រមព្រៀងពីមុនទាំងអស់ (ប្រសិនបើមាន) រវាងលោកអ្នក និងធនាគារ ហើយទាក់ទងទៅនឹងផ្នែក ណាមួយនៃកិច្ចព្រមព្រៀងនេះ ត្រូវបានជំនួសដោយ កិច្ចព្រមព្រៀងនេះ។

## ២២. និយមន័យ

នៅក្នុងកិច្ចព្រមព្រៀងនេះ និយមន័យ មានដូចខាងក្រោម៖

" **សេវាប្រចាំឆ្នាំ** " ជាថ្លៃសេវាប្រចាំឆ្នាំ ដែលបានកំណត់ជាមុនដោយធនាគារដែលអាចផ្លាស់ប្តូរនៅពេលណាមួយ ដែលលោកអ្នកត្រូវបង់សម្រាប់ប័ណ្ណឥណទានប្រចាំឆ្នាំ។

" **បញ្ជរអនុញ្ញាតអោយដកសាច់ប្រាក់** " ជាការិយាល័យ និង/ឬ ទីតាំងដែលកំណត់ដោយស្ថាប័នសមាជិកប័ណ្ណ ណាមួយ ដែលការដកជាសាច់ប្រាក់អាចធ្វើបានដោយម្ចាស់ប័ណ្ណ។

" **ប័ណ្ណឥណទាន** " ជាប័ណ្ណឥណទានវីសា ឬប័ណ្ណឥណទានអាមេរិកខេនអ៊ិចប្រេស្ស (AMEX) ធនាគារមេយប៊ែង ដែលចេញជូនលោកអ្នក។

" **គណនីប័ណ្ណឥណទាន** " ជាគណនីរបស់លោកអ្នក ដែលបើកជាមួយធនាគារសម្រាប់គោលបំណង នៃលក្ខខណ្ឌទាំងនេះ។

" **កម្រិតឥណទាន** " ជាកម្រិតឥណទានដែលបានកំណត់ក្នុងការប្រើប្រាស់ចំពោះប័ណ្ណឥណទានរបស់លោកអ្នក។

" **ប័ណ្ណមេ** " ជាប័ណ្ណឥណទានដែលបានចេញទៅឲ្យម្ចាស់ប័ណ្ណមេ ដែលចាត់ទុកថាជាប័ណ្ណឥណទានមេសម្រាប់គោលបំណងក្នុងការប្រើប្រាស់គណនីប័ណ្ណឥណទានដែលប័ណ្ណឥណទានរងទាំងអស់និងភ្ជាប់ទៅនឹងគណនីប័ណ្ណឥណទានមេនេះ។

" **ម្ចាស់ប័ណ្ណមេ** " ជាបុគ្គលដែលជាម្ចាស់ប័ណ្ណមេ ឬជាអ្នកដែលស្នើសុំប័ណ្ណឥណទានរង។

" **ម្ចាស់ប័ណ្ណ** " ជាបុគ្គល ដែលធនាគារចេញប័ណ្ណឥណទានឲ្យ ដែលមានឈ្មោះនិងហត្ថលេខារបស់លោកអ្នកនៅលើប័ណ្ណឥណទានដែលជាអ្នកមានសិទ្ធិប្រើប្រាស់និងមានសិទ្ធិអនុញ្ញាតឲ្យរួមបញ្ចូលទាំងម្ចាស់ប័ណ្ណឥណទានរង។

" **ម្ចាស់ប័ណ្ណរង** " ជាបុគ្គលម្នាក់ត្រូវបានអនុញ្ញាតដោយម្ចាស់ប័ណ្ណឥណទានមេ និងបានអនុម័តដោយធនាគារក្នុងការផ្តល់នូវប័ណ្ណឥណទានរង។

" **ប័ណ្ណឥណទានរង** " ជាប័ណ្ណឥណទានដែលចេញទៅឲ្យម្ចាស់ប័ណ្ណឥណទានរង លើប័ណ្ណឥណទានដែលចេញទៅឲ្យម្ចាស់ប័ណ្ណមេ (ដែលនឹងត្រូវចាត់ទុកថាជា ប័ណ្ណឥណទានមេ) និងត្រូវបានភ្ជាប់ទៅគណនីប័ណ្ណ ឥណទានរបស់ម្ចាស់ប័ណ្ណឥណទានមេ។

" **ពេលចេញវិក្កយបត្រ** " ជារយៈពេលនៃការចេញរបាយការណ៍ប្រតិបត្តិការប្រចាំខែនីមួយៗរបស់គណនីឬដែលមាននៅក្នុងរបាយការណ៍ប្រចាំខែនៃគណនី ហើយមានកត់ត្រានូវរាល់ការទិញទំនិញ និង/ឬ សេវាកម្ម និងការដកសាច់ប្រាក់ ដែលបានធ្វើឡើង ដោយប្រើប័ណ្ណឥណទាន ព្រមទាំងថ្លៃសេវា និងកម្រៃដែលកើតឡើង ចំពោះលោកអ្នក នៅក្នុងរបាយការណ៍ប្រតិបត្តិការប្រចាំខែនៃគណនី។

" **កាលបរិច្ឆេទផុតកំណត់** " ក្នុងបរិបទ ពេលចេញវិក្កយបត្រ គឺមានរយៈពេលដប់ប្រាំ (១៥)ថ្ងៃ ចាប់ពីថ្ងៃបិទបញ្ជីនៃពេលចេញវិក្កយបត្រដូចមានចែងនៅក្នុងរបាយការណ៍គណនី ប្រចាំខែ។

" **ការទូទាត់អប្បបរមា** " ជាការទូទាត់ប្រាក់តាមចំនួនអប្បបរមាណាមួយប្រចាំខែ ដែលត្រូវទូទាត់នៅក្នុងកាលបរិច្ឆេទកំណត់។

" **កាលបរិច្ឆេទផុតកំណត់បង់ប្រាក់** " ជាការទូទាត់ណាមួយដែលហួសក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃចាប់ពីថ្ងៃបិទបញ្ជីនៃរយៈពេលនៃការចេញរបាយការណ៍បង់ប្រាក់ដែលបានបង្ហាញនៅក្នុងរបាយការណ៍ ប្រតិបត្តិការ។

" **អាជីវករដែលបានអនុញ្ញាត/ជាវីករ** " ជាអាជីវករឬបុគ្គលផ្សេងទៀតឬក្រុមហ៊ុន ឬសាជីវកម្មណាមួយដែលបានធ្វើកិច្ចព្រមព្រៀងជាមួយធនាគារ ឬជាមួយក្រុមហ៊ុន វីសា (Visa) ឬក្រុមហ៊ុនអាមេរិកខេនអ៊ិចប្រេស្ស (AMEX) ប្រសិនជាមានដែលទទួលយកប័ណ្ណឥណទាន។

" **ធនាគារ** " ឬ " **ពួកយើង** " ឬ " **យើងខ្ញុំ** " មានន័យថា ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី។

" **ថ្ងៃធ្វើអាជីវកម្ម** " ជាថ្ងៃដែលធនាគារបើកអាជីវកម្មទូទៅ។

" **ការដកសាច់ប្រាក់** " ជាការដកសាច់ប្រាក់ ដែលធ្វើឡើងតាមរយៈការស្នើសុំដោយការបំពេញឯកសារដកប្រាក់។

" **ឯកសារដកប្រាក់** " មានន័យថាទម្រង់ ដែលផ្តល់ដោយធនាគារនៅសាខា ដែលបានអនុញ្ញាតឲ្យដកសាច់ប្រាក់សម្រាប់គោលបំណងនៃការកត់ត្រាការបញ្ជាក់ និងភស្តុតាងនៃការដកសាច់ប្រាក់ដោយលោកអ្នក តាមរយៈការប្រើប្រាស់

TERMS & CONDITIONS

Maybank

ប័ណ្ណឥណទានដែលត្រូវបានកាត់ចេញពីគណនីប័ណ្ណឥណទានរបស់លោកអ្នក។

" **ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ(ATM)** " មានន័យថាម៉ាស៊ីនដែលបំពាក់ដោយកុំព្យូទ័រ ដែលអាចធ្វើប្រតិបត្តិការបញ្ចេញសាច់ប្រាក់ និងផ្តល់សេវាធនាគារផ្សេងទៀត និងមុខងារផ្សេងៗដែលបានកំណត់សម្រាប់ការប្រើប្រាស់របស់ម្ចាស់ប័ណ្ណ។

" **CHIP Reading Terminal** " មានន័យថាជាម៉ាស៊ីនដែលមានសមត្ថភាពក្នុងការអាន CHIP នៅលើប័ណ្ណឥណទាន។

" **លេខសម្ងាត់** " ជាលេខកូដណាមួយ ដែលធនាគារចេញជូនលោកអ្នក ឬបានជ្រើសរើសដោយលោកអ្នក ដើម្បីអនុញ្ញាតឲ្យលោកអ្នកមានសិទ្ធិទទួលបានសេវាកម្មក្នុងការប្រើប្រាស់ប័ណ្ណឥណទាន។

" **រង្វាន់** " រួមមានការសន្សំពិន្ទុការចាប់រង្វាន់រង្វាន់ប្រាក់សុទ្ធនិងរង្វាន់ផ្សេងៗទៀត ដែលធនាគារផ្តល់ជូននាពេលណាមួយ។

" **Sale Draft** " ឬ " របាយការណ៍នៃការទិញ " មានន័យថាទម្រង់ឯកសារ ដែលចេញដោយធនាគារ ទៅឲ្យអាជីវករដើម្បីបញ្ជាក់ ពីការទិញទំនិញ ឬសេវាកម្ម របស់ម្ចាស់ប័ណ្ណតាមរយៈការប្រើប្រាស់ប័ណ្ណឥណទាន។

" **សម្ព័ន្ធធនាគារ** " មានន័យថាសាជីវកម្មដែលពាក់ព័ន្ធនឹងសម្ព័ន្ធធនាគារនិងក្រុមហ៊ុនដែលពាក់ព័ន្ធទាំងអស់របស់សម្ព័ន្ធធនាគារ។

" **សមតុល្យថ្មីសរុប** " ជាចំនួនទឹកប្រាក់សរុបដែលកើតមានក្នុងរយៈពេលនៃការចេញរបាយការណ៍ហើយចំនួនទឹកប្រាក់សរុបដែលបានកើតឡើងក្នុងរយៈពេលនៃការចេញរបាយការណ៍មាន៖

១) សមតុល្យដែលមិនបានបង់ក្នុងរយៈពេលនៃការចេញរបាយការណ៍ពីខែមុនៗ

២) ចំនួនទឹកប្រាក់សរុបដែលកើតមានឡើងពីការទិញទំនិញ និង/ឬ សេវាកម្ម ឬការដកសាច់ប្រាក់ ដែលបានធ្វើឡើងដោយម្ចាស់ប័ណ្ណ ឬដោយការប្រើប្រាស់ប័ណ្ណឥណទាន ដោយរួមបញ្ចូល ទាំងថ្លៃសេវា និងកម្រៃផ្សេងៗ ដែលយកដោយធនាគារឬជាចំនួនទឹកប្រាក់ដែលលោកអ្នកមិនបានទូទាត់សងគ្រប់ចំនួនក៏បានដាក់បញ្ចូលទៅ ក្នុងគណនីប័ណ្ណឥណទានក្នុងរយៈពេលនៃការចេញរបាយការណ៍នៅក្នុងរយៈពេលជាក់លាក់មួយ។

" **Smart Recycling Machin (SRM)** " មានន័យថាម៉ាស៊ីនដែលបំពាក់ដោយកុំព្យូទ័រដែលអាចធ្វើប្រតិបត្តិការដាក់ប្រាក់ហើយមកបញ្ចេញសាច់ប្រាក់ដែលបានដាក់នោះសម្រាប់អតិថិជនប្រើប្រាស់និងផ្តល់នូវសេវាធនាគារផ្សេងទៀតនិងមុខងារផ្សេងៗ ដែលបាន កំណត់សម្រាប់ការប្រើប្រាស់ របស់ម្ចាស់ប័ណ្ណ។

" **ការបង្វិលសងប្រាក់ពន្ធវិញ** " មានន័យថាការបង្វិលសងនៃចំនួនពន្ធដែលបានមកពីការទិញណាមួយដែលធ្វើឡើងដោយសាច់ប្រាក់ ប័ណ្ណឥណពន្ធ ឬប័ណ្ណឥណទានដែលមានសិទ្ធិទទួលបានការបង្វិលសងពន្ធ។

**២៣. FATCA និង CRS**

យើងខ្ញុំនឹងផ្តល់ដំណឹងជូនធនាគារ មេយប៊ែង ក្នុងរយៈពេល៣០ថ្ងៃ ពីការផ្លាស់ប្តូរណាមួយ ក្នុងកាលៈទេសៈដែលប៉ះពាល់ដល់ពន្ធ ឬពាក់ព័ន្ធនឹងច្បាប់អនុលោមតាមពន្ធគណនេយ្យ (FATCA)។ ដូចនេះយើងខ្ញុំនឹងផ្តល់នូវការបញ្ជាក់ និងការប្រកាសបច្ចុប្បន្នភាពនៅសាខាណាមួយនៃធនាគារ មេយប៊ែង ក្នុងរយៈពេល៣០ថ្ងៃនៃការផ្លាស់ប្តូរ។

**២៤. ការបោះបង់សិទ្ធិ**

អតិថិជន ឬម្ចាស់គណនីបានផ្តល់សច្ចាប័នចំពោះ ខ និងលក្ខខណ្ឌ ដូចដែលបានបង្ហាញនៅក្នុង ខ និងលក្ខខណ្ឌ ឬ នៅក្នុង ពាក្យស្នើសុំនិង/ឬ ឯកសារដែលពាក់ព័ន្ធផ្សេងៗទៀត និងយល់ព្រមលះបង់សិទ្ធិទាំងអស់ដែលមាននៅក្នុងប្រកាសលេខ ០០៦៧ ស្តីពីខសន្យាមិនសុចរិត ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០២២ និង មាត្រា ៣៦០ មាត្រា ៣៦២ និង ៣៦៣ នៃ ក្រមរដ្ឋប្បវេណី។

TERMS & CONDITIONS

Maybank

ឧបសម្ព័ន្ធ ១-កម្រៃហិរញ្ញវត្ថុ

| ពិពណ៌នា | អត្រាការប្រាក់ | |
|---|---|---|
| | ផ្លាទីនីម (Platinum) | ហ្គោល (Gold) |
| អត្រាការប្រាក់លើការទិញទំនិញ | ១៨% ក្នុងមួយឆ្នាំ | ១៨% ក្នុងមួយឆ្នាំ |
| អត្រាការប្រាក់លើការដកសាច់ប្រាក់ | ២៤% ក្នុងមួយឆ្នាំ | ២៤% ក្នុងមួយឆ្នាំ |

*សម្គាល់៖ អត្រាការប្រាក់នឹងត្រូវគិតលើថ្លៃសេវានៃការដកសាច់ប្រាក់សុទ្ធផងដែរ។

ឧបសម្ព័ន្ធ ២-ថ្លៃសេវា និង កម្រៃផ្សេងៗ

| ពិពណ៌នា | ផ្លាទីនីម (Platinum) | ហ្គោល (Gold) |
|---|---|---|
| ថ្លៃសេវាប្រចាំឆ្នាំសម្រាប់ប័ណ្ណឥណទានមេ | ២០០ ដុល្លារអាមេរិក | ៣០ ដុល្លារអាមេរិក |
| ថ្លៃសេវាប្រចាំឆ្នាំសម្រាប់ប័ណ្ណឥណទានរង | ១០០ ដុល្លារអាមេរិក | ១៥ ដុល្លារអាមេរិក |
| ថ្លៃសេវាចំពោះការទូទាត់យឺត | ១% នៃសមតុល្យជំពាក់សរុបឬ<br>ទឹកប្រាក់អប្បបរមា១០ដុល្លារអាមេរិក | ១% នៃសមតុល្យជំពាក់សរុបឬ<br>ទឹកប្រាក់អប្បបរមា ១០ដុល្លារអាមេរិក |
| ថ្លៃសេវាលើការដកសាច់ប្រាក់សុទ្ធ | ៥% នៃសមតុល្យជំពាក់សរុបឬ<br>ទឹកប្រាក់អប្បបរមា ៥ ដុល្លារអាមេរិក | ៥% នៃសមតុល្យជំពាក់សរុបឬ<br>ទឹកប្រាក់អប្បបរមា ៥ ដុល្លារអាមេរិក |
| ថ្លៃសេវាក្នុងការផ្លាស់ប្តូរប័ណ្ណ | ១៥ ដុល្លារអាមេរិក | ១៥ ដុល្លារអាមេរិក |
| ថ្លៃសេវាលើការប្តូររូបិយប័ណ្ណបរទេស | ២% | ២% |
| ថ្លៃសេវាលើដំណើរការ Chargeback | ១០ ដុល្លារអាមេរិក | ១០ ដុល្លារអាមេរិក |
| ថ្លៃសេវាបោះពុម្ពរបាយការណ៍ឡើងវិញ | ឥតគិតថ្លៃ | ២ ដុល្លារអាមេរិក |
| ថ្លៃសេវាលុបចោលប័ណ្ណ<br>(ក្នុងរយៈពេល ៣ខែបន្ទាប់ពីការចេញប័ណ្ណ) | ២០ ដុល្លារអាមេរិក | ២០ ដុល្លារអាមេរិក |
| ថ្លៃសេវាចំពោះការបង្វិលសង នៃប្រាក់ពន្ធពីប័ណ្ណទៅក្នុងគណនីចរន្ត / សន្សំ | 0.៥% នៃសមតុល្យបង្វិលសងសរុបឬ<br>ទឹកប្រាក់អប្បបរមា១០ដុល្លារអាមេរិក | 0.៥% នៃសមតុល្យបង្វិលសងសរុបឬ<br>ទឹកប្រាក់អប្បបរមា១០ដុល្លារអាមេរិក |